ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**គណៈកម្មាធិការប្រឡងថ្នាក់ជាតិ**
**សម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល**

លេខ:........១៦៨....../២៥ គបជ

ថ្ងៃពុធ ១៣រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងចេញថ្នាក់ជាតិ សម្រាប់និស្សិតបញ្ចប់ការសិក្សា នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល សម្រាប់ឆ្នាំ២០២៥ សម័យប្រឡងថ្ងៃទី១៣-១៤ ខែកញ្ញា ឆ្នាំ២០២៥

គណៈកម្មាធិការប្រឡងថ្នាក់ជាតិ សម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល សូមជម្រាបដល់គ្រប់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល និងនិស្សិតដែលបានបញ្ចប់ការសិក្សាទាំងអស់ ឱ្យបានជ្រាបថា សម្រាប់ឆ្នាំ២០២៥នេះ គណៈកម្មាធិការប្រឡងថ្នាក់ជាតិនឹងរៀបចំការប្រឡងចេញថ្នាក់ជាតិ ដោយធ្វើការប្រឡងតែផ្នែកទ្រឹស្តី (MCQ) ប៉ុណ្ណោះ។ និស្សិតទាំងអស់ត្រូវប្រឡងជាប់ក្នុងការប្រឡងផ្នែកជំនាញគ្លីនិក នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលសាមីជាមុនសិន ទើបមានសិទ្ធិចូលរួមការប្រឡងចេញថ្នាក់ជាតិ ដែលមានតែផ្នែកទ្រឹស្តី (MCQ) បាន លើកលែងតែនិស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រសុខភាពសាធារណៈ។

ការប្រឡងចេញថ្នាក់ជាតិនេះ គឺសម្រាប់និស្សិតថ្នាក់វេជ្ជបណ្ឌិតទូទៅ បរិញ្ញាបត្រឱសថ ទន្តបណ្ឌិតទូទៅ បរិញ្ញាបត្រគិលានុបដ្ឋាក បរិញ្ញាបត្រឆ្មប បរិញ្ញាបត្របច្ចេកទេសមន្ទីរពិសោធន៍បណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង បរិញ្ញាបត្រសុខភាពសាធារណៈ បរិញ្ញាបត្រគិលានុបដ្ឋាក-ឆ្មប បរិញ្ញាបត្រគិលានុបដ្ឋាកបណ្តុះបណ្តាលបន្តពីថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រឆ្មបបណ្តុះបណ្តាលបន្តពីថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រឱសថបន្តពីឱសថការីមធ្យម បរិញ្ញាបត្រគិលានុបដ្ឋាកសណ្តំ ប្រពោធនកម្ម និងសង្គ្រោះបន្ទាន់បណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង បរិញ្ញាបត្រព្យាបាលដោយចលនាបណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង បរិញ្ញាបត្ររងគិលានុបដ្ឋាក បរិញ្ញាបត្ររងឆ្មប បរិញ្ញាបត្ររងទន្តគិលានុបដ្ឋាក បរិញ្ញាបត្ររងបច្ចេកទេសមន្ទីរពិសោធន៍ បរិញ្ញាបត្ររងព្យាបាលដោយចលនា បរិញ្ញាបត្ររងបច្ចេកទេសវិទ្យុសាស្ត្រ និងឱសថការីមធ្យមៈ

- បេក្ខជនដែលបានបញ្ចប់ការសិក្សាជាប់ ទាំងទ្រឹស្តី និងជំនាញគ្លីនិក (OSCE) នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាលក្នុងឆ្នាំសិក្សា២០២៣-២០២៤ បេក្ខជនដែលប្រឡងធ្លាក់ក្នុងការប្រឡងថ្នាក់ជាតិកន្លងមក និងបេក្ខជនដែលមិនទាន់បានចូលរួមប្រឡងចេញថ្នាក់ជាតិ។

- បេក្ខជនដែលប្រឡងធ្លាក់ (មិនគិតពីចំនួនដងនៃការធ្លាក់) ឬមិនទាន់បានប្រឡងចេញថ្នាក់ជាតិទាំងអស់កន្លងមក ត្រូវចូលរួមប្រឡងចេញថ្នាក់ជាតិឱ្យអស់នៅឆ្នាំ២០២៥ និងឆ្នាំ២០២៦ ហើយចាប់ពីឆ្នាំ២០២៧តទៅ បេក្ខជនដែលមិនបានចូលរួមប្រឡងចេញថ្នាក់ជាតិសោះក្នុងរយៈពេល៣ឆ្នាំបន្ទាប់ពីបានប្រឡងបញ្ចប់ការសិក្សាផ្ទៃក្នុងពីគ្រឹះស្ថានសាមីមិនអនុញ្ញាតឱ្យចូលរួមប្រឡងចេញថ្នាក់ជាតិឡើយ លើកលែងតែនិស្សិតបានចូលរួមវគ្គបំប៉នរយៈពេលមួយឆ្នាំ នៅគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាលសាមីបន្ថែម ទើបមានសិទ្ធិចូលរួមប្រឡង។

**បញ្ជាក់៖**

១. គណៈកម្មាធិការប្រឡងថ្នាក់ជាតិនឹងធ្វើការប្រឡងចេញថ្នាក់ជាតិតែផ្នែកទ្រឹស្តីប៉ុណ្ណោះ ចំពោះនិស្សិតដែលមិនទាន់បានចូលរួមក្នុងការប្រឡងចេញថ្នាក់ជាតិកន្លងមក និស្សិតដែលបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាលក្នុងឆ្នាំសិក្សា២០២៣-២០២៤ និងបេក្ខជនដែលធ្លាប់ប្រឡងធ្លាក់ក្នុងការប្រឡងចេញថ្នាក់ជាតិក្នុងឆ្នាំកន្លងមក។

២. បេក្ខជនដែលមិនទាន់បានបញ្ចប់ការធ្វើសារណា ឬនិក្ខេបបទ ត្រូវបានអនុញ្ញាតឱ្យជំពាក់ ដើម្បីបានដាក់ពាក្យសុំចូលរួមការប្រឡងចេញថ្នាក់ជាតិបាន។ ប៉ុន្តែបេក្ខជននោះត្រូវបញ្ចប់ការធ្វើសារណា ឬនិក្ខេបបទក្នុងរយៈពេល០៣ (បី) ខែយ៉ាងយូរ ក្រោយពេលប្រកាសលទ្ធផល។

៣. គណៈកម្មាធិការប្រឡងថ្នាក់ជាតិនឹងរៀបចំការប្រឡងចេញថ្នាក់ជាតិចំនួន០២(ពីរ)ដង ក្នុងមួយឆ្នាំ។

៤. ការប្រឡងចេញថ្នាក់ជាតិ ត្រូវអនុវត្តតាមពិធីសារប្រឡងសម្រាប់ការប្រឡងចេញថ្នាក់ជាតិ ចំពោះនិស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់វេជ្ជបណ្ឌិតទូទៅ ទន្តបណ្ឌិតទូទៅ បរិញ្ញាបត្រឱសថ បរិញ្ញាបត្រគិលានុបដ្ឋាក បរិញ្ញាបត្រឆ្មប បរិញ្ញាបត្របច្ចេកទេសមន្ទីរពិសោធន៍បណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង បរិញ្ញាបត្រសុខភាពសាធារណៈ បរិញ្ញាបត្រគិលានុបដ្ឋាក-ឆ្មប បរិញ្ញាបត្រគិលានុបដ្ឋាកបណ្តុះបណ្តាលបន្តពីថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក បរិញ្ញាបត្រឆ្មបបណ្តុះបណ្តាលបន្តពីថ្នាក់បរិញ្ញាបត្ររងឆ្មប បរិញ្ញាបត្រឱសថបន្តពីឱសថការីមធ្យម បរិញ្ញាបត្រគិលានុបដ្ឋាកសណ្តំ ប្រពោធនកម្ម និងសង្គ្រោះបន្ទាន់បណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង បរិញ្ញាបត្រព្យាបាលដោយចលនាបណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង បរិញ្ញាបត្ររងព្យាបាលដោយចលនា បរិញ្ញាបត្ររងគិលានុបដ្ឋាក បរិញ្ញាបត្ររងឆ្មប បរិញ្ញាបត្ររងទន្តគិលានុបដ្ឋាក បរិញ្ញាបត្ររងបច្ចេកទេសមន្ទីរពិសោធន៍ បរិញ្ញាបត្ររងបច្ចេកទេសវិទ្យុសាស្ត្រ និងឱសថការីមធ្យម។

## ១.វិញ្ញាសា កាលបរិច្ឆេទ និងទីកន្លែងប្រឡង

### ១.១. កាលបរិច្ឆេទប្រឡង និងវិញ្ញាសាប្រឡង៖

### ក. កាលបរិច្ឆេទប្រឡង និងមុខជំនាញ៖

វិញ្ញាសាប្រឡងផ្នែកទ្រឹស្តីជាប្រភេទសំណួរ Multiple Choice Question (MCQ) មានចំនួន២០០សំណួរ ដែលសំណួរនីមួយៗ មានចម្លើយត្រឹមត្រូវតែមួយគត់។ ការប្រឡងសំណេរនឹងប្រព្រឹត្តទៅតាមកាលបរិច្ឆេទ និងមុខជំនាញ ដូចខាងក្រោម៖

- ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៥៖ សម្រាប់ថ្នាក់វេជ្ជបណ្ឌិតទូទៅ ទន្តបណ្ឌិតទូទៅ បរិញ្ញាបត្រឱសថ បរិញ្ញាបត្រឱសថបន្តពីឱសថការីមធ្យម ឱសថការីមធ្យម បរិញ្ញាបត្ររងឆ្មប បរិញ្ញាបត្ររងបច្ចេកទេសវិទ្យុសាស្ត្រ បរិញ្ញាបត្រគិលានុបដ្ឋាក បរិញ្ញាបត្រគិលានុបដ្ឋាកបណ្តុះបណ្តាលបន្តពីថ្នាក់បរិញ្ញាបត្ររង និងបរិញ្ញាបត្រគិលានុបដ្ឋាកសណ្តំ ប្រពោធនកម្ម និងសង្គ្រោះបន្ទាន់បណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង។

- ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៥៖ សម្រាប់ថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក បរិញ្ញាបត្រឆ្មប បរិញ្ញាបត្រឆ្មបបន្តពីបរិញ្ញាបត្ររង បរិញ្ញាបត្របច្ចេកទេសមន្ទីរពិសោធន៍បណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង បរិញ្ញាបត្រគិលានុបដ្ឋាក-ឆ្មប បរិញ្ញាបត្រសុខភាពសាធារណៈ បរិញ្ញាបត្ររងទន្តគិលានុបដ្ឋាក បរិញ្ញាបត្ររងព្យាបាលដោយចលនា បរិញ្ញាបត្ររងបច្ចេកទេសមន្ទីរពិសោធន៍ និងបរិញ្ញាបត្រព្យាបាលដោយចលនាបណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង។

ខ.វិញ្ញាសាប្រឡង៖

❖ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៥៖

១. ចាប់ពីម៉ោង ១៣:៣០ នាទី ដល់ម៉ោង ១៥:០០ នាទី៖

ក. ថ្នាក់វេជ្ជបណ្ឌិតទូទៅ៖

- មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រ — ២០ សំណួរ MCQ
- ជំងឺទូទៅ — ៤០ សំណួរ MCQ
- ជំងឺវះកាត់ — ៤០ សំណួរ MCQ

ខ.ថ្នាក់ទន្តបណ្ឌិតទូទៅ៖

- វិទ្យាសាស្ត្រមូលដ្ឋាន — ៤០ សំណួរ MCQ
- ក្រមសីលធម៌ ឥរិយាបថ និងសុខភាពសាធារណៈ — ២០ សំណួរ MCQ
- ការពិនិត្យជំងឺមាត់ធ្មេញ — ៤០ សំណួរ MCQ

គ. ថ្នាក់បរិញ្ញាបត្រឱសថ និងបរិញ្ញាបត្រឱសថបណ្តុះបណ្តាលបន្តពីឱសថការីមធ្យម៖

- មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រឥរិយាបថ — ៤០ សំណួរ MCQ
- ឱសថសាស្ត្រគ្លីនិក និងការអនុវត្តផ្នែកឱសថ — ៦០ សំណួរ MCQ

ឃ. ថ្នាក់ឱសថការីមធ្យម៖

- វិទ្យាសាស្ត្រជីវវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រឥរិយាបថ — ៤០ សំណួរ MCQ
- ឱសថសាស្ត្រគ្លីនិក និងការអនុវត្តផ្នែកឱសថ — ៦០ សំណួរ MCQ

ង.ថ្នាក់បរិញ្ញាបត្ររងឆ្មប៖

- សង្គម អេពីដេមីសាស្ត្រនិងបរិបទវប្បធម៌នៃការថែទាំមាតានិងទារកទើបកើត — ៣០ សំណួរ MCQ
- ការថែទាំមុនពេលមានផ្ទៃពោះ និងសេវាពន្យាកំណើត/ផែនការគ្រួសារ — ៣០ សំណួរ MCQ
- ការថែទាំក្នុងអំឡុងពេលមានផ្ទៃពោះ — ៤០ សំណួរ MCQ

ច. ថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសវិទ្យុសាស្ត្រ ៖

- សំណួរចំនួន ១០០សំណួរ (MCQ) ត្រូវធ្វើការជ្រើសរើសចេញពីធនាគារ តាមរយៈការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ ដោយមិនចាំបាច់ជ្រើសរើសតាមមុខវិជ្ជាឡើយ។

ឆ.ថ្នាក់បរិញ្ញាបត្រគិលានុបដ្ឋាក និងបរិញ្ញាបត្រគិលានុបដ្ឋាកបណ្តុះបណ្តាលបន្តពីថ្នាក់បរិញ្ញាបត្ររង៖

- វិទ្យាសាស្ត្រមូលដ្ឋាន — ៣០ សំណួរ MCQ
- វិទ្យាសាស្ត្រមូលដ្ឋានគ្រឹះ — ១០ សំណួរ MCQ
- បែបបទថែទាំ — ១០ សំណួរ MCQ
- ការថែទាំម្តាយ និងទារក — ៥០ សំណួរ MCQ

ជ. បរិញ្ញាបត្រគិលានុបដ្ឋាកសណ្តំ ប្រពោធនកម្ម និងសង្គ្រោះបន្ទាន់បណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង៖

- Anesthesia — ៥០ សំណួរ MCQ
- Critical Care — ៣០ សំណួរ MCQ
- Emergency — ២០ សំណួរ MCQ

២. ចាប់ពីម៉ោង ១៥:៣០នាទី ដល់ម៉ោង ១៧:០០នាទី ៖

ក. ថ្នាក់វេជ្ជបណ្ឌិតទូទៅ៖

- មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រ — ២០ សំណួរ MCQ
- ជំងឺកុមារ — ៤០ សំណួរ MCQ
- សម្ភព និងរោគស្ត្រី — ៤០ សំណួរ MCQ

ខ. ថ្នាក់ទន្តបណ្ឌិតទូទៅ៖

- ការព្យាបាលជំងឺមាត់ធ្មេញ — ១០០ សំណួរ MCQ

គ. ថ្នាក់បរិញ្ញាបត្រឱសថ និងបរិញ្ញាបត្រឱសថបណ្តុះបណ្តាលបន្តពីឱសថការីមធ្យម៖

- វិទ្យាសាស្ត្រឱសថ — ១០០ សំណួរ MCQ

ឃ. ថ្នាក់ឱសថការីមធ្យម៖

- វិទ្យាសាស្ត្រឱសថ — ១០០ សំណួរ MCQ

ង. ថ្នាក់បរិញ្ញាបត្ររងឆ្មប៖

- ការថែទាំទារកទើបកើតក្រោយសម្រាល — ២៥ សំណួរ MCQ
- ការថែទាំដល់ស្ត្រីក្រោយសម្រាល — ២៥ សំណួរ MCQ
- ការថែទាំក្នុងអំឡុងពេលឈឺពោះសម្រាលនិងពេលសម្រាល — ៥០ សំណួរ MCQ

ច. ថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសវិទ្យុសាស្ត្រ ៖

- សំណួរចំនួន ១០០សំណួរ (MCQ) ត្រូវធ្វើការជ្រើសរើសចេញពីធនាគារ តាមរយៈការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ ដោយមិនចាំបាច់ជ្រើសរើសតាមមុខវិជ្ជាឡើយ។

ឆ.ថ្នាក់បរិញ្ញាបត្រគិលានុបដ្ឋាក និងបរិញ្ញាបត្រគិលានុបដ្ឋាកបណ្តុះបណ្តាលបន្តពីថ្នាក់បរិញ្ញាបត្ររង៖

- ការថែទាំមនុស្សពេញវ័យ និងការលើកកម្ពស់ទម្រង់ការថែទាំ — ១០០ សំណួរ MCQ

ជ. បរិញ្ញាបត្រគិលានុបដ្ឋាកសណ្តំ ប្រពោធនកម្ម និងសង្គ្រោះបន្ទាន់បណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង៖

- Critical Thinking and Professionalism — ៣០ សំណួរ MCQ
- Research and Statistics — ៣០ សំណួរ MCQ
- Management for Anesthesia — ៤០ សំណួរ MCQ

❖ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៥៖

១. ចាប់ពីម៉ោង ១៣:៣០ នាទី ដល់ម៉ោង ១៥:០០ នាទី៖

ក. ថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក៖

- វិទ្យាសាស្ត្រមូលដ្ឋាន — ៣០ សំណួរ MCQ
- វិទ្យាសាស្ត្រមូលដ្ឋានគ្រឹះ — ១០ សំណួរ MCQ
- បែបបទថែទាំ — ១០ សំណួរ MCQ
- ការថែទាំម្តាយនិងទារក — ៥០ សំណួរ MCQ

ខ. ថ្នាក់បរិញ្ញាបត្រឆ្មប និងបរិញ្ញាបត្រឆ្មបបណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង៖
- សង្គមអេពីដេមីសាស្ត្របរិបទវប្បធម៌នៃការថែទាំមាតានិងទារកទើបកើត ១០ សំណួរ MCQ
- ការថែទាំមុនពេលមានផ្ទៃពោះ សេវាពន្យារកំណើត/ផែនការគ្រួសារ ២៥ សំណួរ MCQ
- ការថែទាំក្នុងអំឡុងពេលមានផ្ទៃពោះ ៤០ សំណួរ MCQ
- ការសម្របសម្រួលលើការថែទាំការរំលូត ២៥ សំណួរ MCQ

គ. ថ្នាក់បរិញ្ញាបត្របច្ចេកទេសមន្ទីរពិសោធន៍បណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង៖
- វិទ្យាសាស្ត្រមូលដ្ឋាន ៤០ សំណួរ MCQ
- ការគ្រប់គ្រង ភាពជាអ្នកដឹកនាំ និងប្រព័ន្ធគ្រប់គ្រងគុណភាព ៣០ សំណួរ MCQ
- ភាពបន្ទាន់ ជំងឺសុវត្ថិភាព និងសន្តិសុខ ១០ សំណួរ MCQ
- ការស្រាវជ្រាវ ០៥ សំណួរ MCQ
- ការទំនាក់ទំនង និងព័ត៌មានវិទ្យា ០៥ សំណួរ MCQ
- ក្រមសីលធម៌ ១០ សំណួរ MCQ

ឃ. បរិញ្ញាបត្រគិលានុបដ្ឋាក-ឆ្មប៖
- មនុស្សសាស្ត្រ និងសិល្បៈ ២០ សំណួរ MCQ
- ផ្នត់គំនិតរបស់ឆ្មប ១០ សំណួរ MCQ
- វិទ្យាសាស្ត្រធម្មជាតិនៃមនុស្ស ៣០ សំណួរ MCQ
- វិទ្យាសាស្ត្រមូលដ្ឋានគ្រឹះ ២០សំណួរ MCQ
- ការថែទាំជំងឺកុមារ ២០សំណួរ MCQ

ង. ថ្នាក់បរិញ្ញាបត្ររងទន្តគិលានុបដ្ឋាក៖
- វិទ្យាសាស្ត្រមូលដ្ឋាន ៣០ សំណួរ MCQ
- វិទ្យាសាស្ត្រមូលដ្ឋានគ្រឹះ ៣០ សំណួរ MCQ
- ការលើកកម្ពស់ទម្រង់ការថែទាំ ៤០ សំណួរ MCQ

ច. ថ្នាក់បរិញ្ញាបត្ររងព្យាបាលដោយចលនា៖
- សំណួរចំនួន ១០០សំណួរ (MCQ) ត្រូវធ្វើការជ្រើសរើសចេញពីធនាគារ តាមរយៈការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ ដោយមិនចាំបាច់ជ្រើសរើសតាមមុខវិជ្ជាឡើយ។

ឆ. ថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសមន្ទីរពិសោធន៍៖
- វិទ្យាសាស្ត្រមូលដ្ឋាន ៤០ សំណួរ MCQ
- ការអនុវត្តទូទៅក្នុងមន្ទីរពិសោធន៍ ៥០ សំណួរ MCQ
- ភាពបន្ទាន់ ជំងឺសុវត្ថិភាព និងសន្តិសុខ ១០ សំណួរ MCQ

ជ. បរិញ្ញាបត្រព្យាបាលដោយចលនាបណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង៖
- ជំងឺប្រព័ន្ធប្រសាទ ៥០ សំណួរ MCQ
- ជំងឺសួត និងបេះដូង ៥០ សំណួរ MCQ

ញ.បរិញ្ញាបត្រសុខភាពសាធារណៈ ៖
- វិទ្យាសាស្ត្រមូលដ្ឋាន ៣០ សំណួរ MCQ
- លក្ខខណ្ឌទាក់ទងនិងសុខភាព ៣០ សំណួរ MCQ
- ការឃ្លាំមើល និងការស៊ើបអង្កេត ៤០ សំណួរ MCQ

២. ចាប់ពីម៉ោង ១៥:៣០នាទី ដល់ម៉ោង ១៧:០០នាទី ៖

ក. ថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក៖

- ការថែទាំមនុស្សពេញវ័យ ៥០ សំណួរ MCQ
- ការលើកកម្ពស់ទម្រង់ការថែទាំ ៥០ សំណួរ MCQ

ខ. ថ្នាក់បរិញ្ញាបត្រឆ្មប និងបរិញ្ញាបត្រឆ្មបបណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង៖

- ការថែទាំក្នុងអំឡុងពេលឈឺពោះសម្រាលនិងពេលសម្រាល ៤០ សំណួរ MCQ
- ការថែទាំដល់ស្ត្រីក្រោយសម្រាល ៣០ សំណួរ MCQ
- ការថែទាំទារកទើបកើតក្រោយសម្រាល ៣០ សំណួរ MCQ

គ. ថ្នាក់បរិញ្ញាបត្របច្ចេកទេសមន្ទីរពិសោធន៍បណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង៖

- ការអនុវត្តទូទៅក្នុងមន្ទីរពិសោធន៍ ១០០ សំណួរ MCQ

ឃ. បរិញ្ញាបត្រគិលានុបដ្ឋាក-ឆ្មប៖

- ឱសថវិទ្យា ១០ សំណួរ MCQ
- ជំងឺទាក់ទងទៅមាតា ២០ សំណួរ MCQ
- ជំនាញឆ្មប ៣០ សំណួរ MCQ
- ការថែទាំសុខភាពមាតា ១០ សំណួរ MCQ
- ការគ្រប់គ្រងការងារឆ្មប ២០ សំណួរ MCQ
- ការអប់រំសុខភាព ១០ សំណួរ MCQ

ង. ថ្នាក់បរិញ្ញាបត្ររងទន្តគិលានុបដ្ឋាក៖

- បែបបទនៃការថែទាំ ១០ សំណួរ MCQ
- ប្រធានបទធ្មេញ ៩០ សំណួរ MCQ

ច. ថ្នាក់បរិញ្ញាបត្ររងព្យាបាលដោយចលនា៖

- សំណួរចំនួន ១០០សំណួរ (MCQ) ត្រូវធ្វើការជ្រើសរើសចេញពីធនាគារ តាមរយៈការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ ដោយមិនចាំបាច់ជ្រើសរើសតាមមុខវិជ្ជាឡើយ។

ឆ. ថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសមន្ទីរពិសោធន៍៖

- ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ និងប្រព័ន្ធគ្រប់គ្រងគុណភាព ៣០ សំណួរ MCQ
- ការអនុវត្តទូទៅក្នុងមន្ទីរពិសោធន៍ ៥៥ សំណួរ MCQ
- ការទំនាក់ទំនង និងព័ត៌មានវិទ្យា ០៥ សំណួរ MCQ
- ក្រមសីលធម៌ ១០ សំណួរ MCQ

ជ.បរិញ្ញាបត្រព្យាបាលដោយចលនាបណ្តុះបណ្តាលបន្តពីបរិញ្ញាបត្ររង៖

- ជំងឺសន្លាក់ និងសាច់ដុំ ៦០ សំណួរ MCQ
- ការស្តារលទ្ធភាពពលកម្មនៅក្នុងសហគមន៍ ១០ សំណួរ MCQ
- ការប្រើប្រាស់កៅអីមានកង់ ១០ សំណួរ MCQ
- ជំងឺកុមារ និងសុខភាពស្ត្រី ២០ សំណួរ MCQ

ញ.បរិញ្ញាបត្រសុខភាពសាធារណៈ៖

- ការអន្តរាគមន៍សុខភាពសាធារណៈ និងការស្រាវជ្រាវ ៥០ សំណួរ MCQ
- ការគ្រប់គ្រង ៥០ សំណួរ MCQ

១.២.ទីកន្លែងប្រឡង៖

ការប្រឡងទ្រឹស្តីនឹងប្រព្រឹត្តទៅនៅមណ្ឌលសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ គណៈកម្មាធិការប្រឡងថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាលនឹងជូនព័ត៌មានលម្អិតពីការបែងចែកបន្ទប់រយៈពេលមួយថ្ងៃមុនការប្រឡង។

## ២.សំណុំលិខិតដែលត្រូវបំពេញ

២.១. និស្សិតដែលបានប្រឡងធ្លាក់ក្នុងការប្រឡងចេញថ្នាក់ជាតិកន្លងមក ត្រូវមាន៖

- បង្កាន់ដៃទទួលពាក្យ.......................................................................១ច្បាប់
- ពាក្យសុំចុះឈ្មោះប្រឡង...................................................................១ច្បាប់
- ប្រវត្តិរូបសង្ខេបមានបិទរូបថតថ្មី (៤ x ៦).............................................១ច្បាប់
- បញ្ជីលទ្ធផលប្រឡងចេញថ្នាក់ជាតិទាំងផ្នែកទ្រឹស្តី និងទាំងផ្នែកជំនាញគ្លីនិកក្នុងការប្រឡងចេញថ្នាក់ជាតិកន្លងមក(ដែលផ្តល់ដោយគ្រឹះស្ថានបណ្តុះបណ្តាលសាមី)..........................១ច្បាប់

២.២.និស្សិតដែលមិនទាន់បានចូលរួមក្នុងការប្រឡងចេញថ្នាក់ជាតិកន្លងមក និងនិស្សិតទើបបានបញ្ចប់ការសិក្សានៅឆ្នាំសិក្សា២០២៣-២០២៤ ត្រូវមាន៖

- បង្កាន់ដៃទទួលពាក្យ.......................................................................១ច្បាប់
- ពាក្យសុំចុះឈ្មោះប្រឡង...................................................................១ច្បាប់
- ប្រវត្តិរូបសង្ខេបមានបិទរូបថតថ្មី (៤ x ៦).............................................១ច្បាប់
- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬព្រឹត្តិបត្រពិន្ទុនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចេញដោយនាយកដ្ឋានជំនាញ នៃក្រសួងអប់រំ យុវជន និងកីឡា ឬមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត ឬសញ្ញាបត្រដែលមានតម្លៃស្មើដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ឬគណៈកម្មាធិការវាយតម្លៃកម្រិតសញ្ញាបត្រ និងលិខិតបញ្ជាក់ការសិក្សា ច្បាប់ដើម ឬថតចម្លង (ភ្ជាប់មកជាមួយនូវច្បាប់ដើមដើម្បីផ្ទៀងផ្ទាត់).........................................................................១ច្បាប់
- សញ្ញាបត្រ ឬវិញ្ញាបនបត្របញ្ជាក់ការសិក្សាកម្រិតបរិញ្ញាបត្ររង ឬគ្រូពេទ្យមធ្យម (ករណីនិស្សិតសិក្សាថ្នាក់បន្តពីថ្នាក់បរិញ្ញាបត្ររង ឬថ្នាក់បន្តពីគ្រូពេទ្យមធ្យមសម្រាប់ឆ្នាំសិក្សាដែលមិនតម្រូវឱ្យមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ)..........................................................................១ច្បាប់
- វិញ្ញាបនបត្របញ្ចប់ការសិក្សាដោយជោគជ័យចេញដោយគ្រឹះស្ថានបណ្តុះបណ្តាលសាមី...........១ច្បាប់
- ព្រឹត្តិបត្រពិន្ទុនៃការសិក្សាគ្រប់មុខវិជ្ជា និងគ្រប់ឆ្នាំសិក្សាចេញដោយគ្រឹះស្ថាន.......................១ច្បាប់
- លទ្ធផលប្រឡងថ្នាក់ជាតិចូលរៀនក្នុងវិស័យសុខាភិបាល ឬលទ្ធផលជ្រើសរើសចូលរៀនថ្នាក់ជាតិដែលមានហត្ថលេខាទទួលស្គាល់ដោយគណៈកម្មាធិការប្រឡងថ្នាក់ជាតិ...........................................១ច្បាប់
- លិខិតអនុញ្ញាតឱ្យចូលរៀនដែលមានការទទួលស្គាល់ ដោយក្រសួងសុខាភិបាល និង/ឬក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីដែលនិស្សិតពុំមានឆ្លងកាត់ការប្រឡងជ្រើសរើសចូលរៀនថ្នាក់ជាតិ.....១ច្បាប់
- បញ្ជីលទ្ធផលប្រឡងបញ្ចប់ការសិក្សា ជាប់ទាំងទ្រឹស្តី និងជំនាញគ្លីនិក (OSCE) នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដែលមានអាជ្ញាបណ្ណ ដែលមានការទទួលស្គាល់ដោយក្រសួងសុខាភិបាល និង/ឬក្រសួងអប់រំ យុវជន និងកីឡា.........................................................................១ច្បាប់

### ៣. ទីកន្លែងដាក់ពាក្យ៖

- ❖ បេក្ខជនត្រូវទៅដាក់ពាក្យសុំចូលប្រឡងចេញថ្នាក់ជាតិ ចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៥ វេលាម៉ោង៥:០០នាទីល្ងាច នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដែលមានបេក្ខជនបានបញ្ចប់ការសិក្សា។ គ្រឹះស្ថានបណ្តុះបណ្តាលទាំងអស់ត្រូវបញ្ជូនបញ្ជីឈ្មោះបេក្ខជន (តារាង Excel មានគំរូ)ដែលត្រូវចូលរួមប្រឡងមកលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រឡងថ្នាក់ជាតិឱ្យបានត្រឹម **ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៥** ថ្ងៃត្រង់ជាកំហិត។
- ❖ បេក្ខជនដែលបានបញ្ចប់ការសិក្សានៅអតីតវិទ្យាស្ថានវិទ្យាសាស្ត្រថែទាំ និងអមវេជ្ជសាស្ត្រភ្នំពេញ ត្រូវមកដាក់ពាក្យនៅលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រឡងថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល ដែលមានទីតាំងនៅនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងសុខាភិបាល។
- ❖ សំណុំលិខិតសម្រាប់ដាក់ពាក្យដែលត្រូវបំពេញមានគំរូស្រាប់ នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលនីមួយៗ។
- ❖ បេក្ខជនអាចសាកសួរព័ត៌មានផ្សេងៗទៀត នៅតាមគ្រឹះស្ថានពាក់ព័ន្ធ។

### ៤. ថវិកាដើម្បីចូលរួមចំណែកក្នុងការរៀបចំការប្រឡងចេញថ្នាក់ជាតិ៖

បេក្ខជនដាក់ពាក្យសុំចូលរួមការប្រឡងចេញថ្នាក់ជាតិ ត្រូវបង់ថវិកាចំនួន ១០០.០០០រៀល (មួយរយពាន់រៀលគត់) ក្នុង១នាក់ ដើម្បីរួមចំណែករៀបចំការប្រឡងចេញថ្នាក់ជាតិ។ គ្រឹះស្ថានបណ្តុះបណ្តាលទាំងអស់ត្រូវយកថវិកាដែលទទួលបានពីនិស្សិតបង់ថ្លៃនេះមកដាក់នៅច្រកចេញចូលតែមួយ តាមរយៈគណនេយ្យធនាគាររបស់ក្រសួងសុខាភិបាល។

**បញ្ជាក់៖**

- ក្នុងករណីរកឃើញថា បេក្ខជនក្លែងបន្លំសញ្ញាបត្រ ឬឯកសារពាក់ព័ន្ធ ត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិតនៅតាមគ្រឹះស្ថានសាមីដែលខ្លួនកំពុងរៀនបច្ចុប្បន្ន និងត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន
- បេក្ខជនដែលអនុវត្តផ្ទុយពីសេចក្តីជូនដំណឹងនេះ និងបទបញ្ជាសម្រាប់ការប្រឡងចេញថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាលនេះ ត្រូវកំណត់ឱ្យធ្លាក់ដោយស្វ័យប្រវត្តិ។

**ប្រធានគណៈកម្មាធិការប្រឡងថ្នាក់ជាតិ**
**សម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល**

**សុក ផេង**

ចម្លងជូន៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសុខាភិបាល
-ក្រសួងអប់រំ យុវជន និងកីឡា
-គ្រឹះស្ថានបណ្តុះបណ្តាលពាក់ព័ន្ធ
-ឯកសារ កាលប្បវត្តិ